**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ**

លេខ ៩១៦៣ សរាចរ. កសក

# សេចក្តីណែនាំ
# ស្តីពី
# វិធានការទប់ស្កាត់ការបាត់បង់បរិមាណ និងគុណភាពស្រូវ រដូវវស្សាឆ្នាំ២០១១ នៅក្នុងនិងក្រោយពេលប្រមូលផល

នៅរដូវវស្សាឆ្នាំ២០១១នេះ ដោយទទួលបានអំណោយផលទឹកភ្លៀងតាំងពីដើមរដូវនិងដោយមានការខិតខំប្រឹងប្រែងរបស់បងប្អូនកសិកររួមជាមួយអាជ្ញាធរគ្រប់លំដាប់ថ្នាក់ ព្រមទាំងមានការឧបត្ថម្ភគាំទ្រតាមគ្រប់មធ្យោបាយពីរាជរដ្ឋាភិបាលនោះ ការងារបង្កបង្កើនផលស្រូវមានសន្ទុះលឿនគួរជាទីមោទនៈ ដែលគិតមកទល់ពេលនេះយើងសម្រេចស្ទូងនិងព្រោះបានចំនួន ២.៤៦៧.០២៧ហិកតា ស្មើនឹង ១០៥,៨៨% នៃផែនការ ២.៣៣០.០៨០ហិកតា លើសឆ្នាំមុន ៧៦.៥៥៥ហិកតា បើប្រៀបធៀបរយៈពេលដូចគ្នា។

ទន្ទឹមនឹងលទ្ធផលដ៏គួរឱ្យសង្ឃឹមខាងលើ ដំណាំស្រូវនៅតាមបណ្តាខេត្តមួយចំនួនក៏ត្រូវទទួលរងនូវគ្រោះទឹកជំនន់ជាបន្តបន្ទាប់ ហើយចុងក្រោយនេះគឺការទទួលរងយ៉ាងធ្ងន់ធ្ងរនូវបាតុភូតគ្រោះធម្មជាតិបង្កឡើងដោយទឹកជំនន់ទន្លេមេគង្គនិងទឹកជំនន់ទឹកភ្លៀងពីប៉ែកខាងលើ ដែលគិតត្រឹមថ្ងៃទី២២ ខែវិច្ឆិកា ឆ្នាំ២០១១ បានបង្កការប៉ះពាល់លើផ្ទៃដីសន្ទូងនិងស្រូវពង្រោះចំនួន៤០៥.២៥៥ហិកតា ក្នុងនោះបណ្តាលឱ្យមានការខូចខាតប្រមាណជា ២២៦.៥៤៥ហិកតា។

ស្ថិតក្នុងស្ថានភាពដ៏លំបាកលំបិននេះនិងជាពិសេសក្រោមការចង្អុលបង្ហាញប្រកបដោយគតិបណ្ឌិតរបស់**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា** និងក្រោមកិច្ចសហការដ៏មានប្រសិទ្ធភាពពីក្រសួង ស្ថាប័នពាក់ព័ន្ធ អាជ្ញាធរមូលដ្ឋាន កងកម្លាំងប្រដាប់អាវុធ ប្រជាកសិករ ផលិតករនិងដៃគូអភិវឌ្ឍន៍នានាផងនោះ ការស្តារការខូចខាតតាមរយៈការធ្វើស្រូវប្រដេញទឹកនៅក្រោយពេលទឹកស្រកបាននិងកំពុងដំណើរការយ៉ាងមមាញឹកតាមលទ្ធភាពនិងភូមិសាស្ត្រជាក់ស្តែង ដែលរហូតមកដល់ពេលនេះសម្រេចបានប្រមាណ ១៤,៣២៧ហិកតាហើយ។ ដោយឡែកដំណាំស្រូវដែលមិនរងការខូចខាតប្រមាណ ២.២០៩.៣២៣ហិកតា ក៏កំពុងចេញផ្កា ផ្លែ និងទុំជាបន្តបន្ទាប់ដែលផ្តល់នូវក្តីសង្ឃឹមយ៉ាងក្រៃលែង ហើយដែលប្រជាកសិករខ្លះក៏កំពុងតែប្រមូលផលជាបណ្តើរៗ។

ក្នុងគោលបំណងដើម្បីកាត់បន្ថយនូវការបាត់បង់ស្រូវអង្ករទាំងបរិមាណនិងគុណភាព នៅក្រោយពេលប្រមូលផលដែលធ្វើឱ្យកសិករខាតបង់ផលចំណេញនិងពុំមាននិរន្តរភាពនៅលើទីផ្សារជាតិនិងអន្តរជាតិនោះ ក្រសួងកសិកម្ម រុក្ខា-ប្រមាញ់ និងនេសាទ សូមធ្វើការណែនាំដល់គ្រប់អង្គភាពក្រោមឱវាទនិងមន្ទីរកសិកម្មរាជធានី-ខេត្តទូទាំងប្រទេសត្រូវ

អាស័យដ្ឋានលេខ ២០០ មហាវិថីព្រះនរោត្តម សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន រាជធានីភ្នំពេញ កម្ពុជា
N° 200 Preah Norodom Blvd., Sangkat Toule Basak, Khan Chamkarmon Phnom Penh. Cambodia
ទូរស័ព្ទលេខ : (០២៣) ៧២៦ ១២៨ / ៧២៦ ១២៩ ទូរសារលេខ : (៨៥៥) ២៣-២១៧ ៣២០
Phone : (023) 726 128 / 726 129, Fax . (855) 23 - 217 320

យកចិត្តទុកដាក់ខ្ពស់បំផុតដើម្បីណែនាំដល់កសិករ ផលិតករ និងអ្នកពាក់ព័ន្ធទាំងអស់ឱ្យអនុវត្តនូវវិធានការចាំបាច់និងបន្ទាន់មួយចំនួនដូចខាងក្រោម ៖

១- នៅពេលស្រូវមិនទាន់ទុំល្អ ត្រូវរក្សាឱ្យមានទឹកដក់នៅក្នុងស្រែជានិច្ច។ ការបង្ហូរទឹកចេញ គួរធ្វើនៅពេលដែលគ្រាប់ស្រូវនៅចុងកួរភាគច្រើនដាក់ម្សៅរឹងនិងប្រែពណ៌ទៅជាលឿងឬប្រមាណជា១សប្តាហ៍មុនពេលច្រូតកាត់ ពីព្រោះថាបើខ្វះទឹកស្រូវនឹងដាក់គ្រាប់មិនបានពេញល្អ ធ្វើឱ្យស្កកហើយអង្ករមានពោះសច្រើន។ ផ្ទុយទៅវិញការបង្ហូរទឹកចេញពីស្រែយឺតពេកក៏នឹងធ្វើឱ្យមានការលំបាកក្នុងការច្រូតកាត់និងដឹកជញ្ជូនផងដែរ។

២- ត្រូវច្រូតស្រូវនៅពេលដែលស្រូវទុំល្អ គឺនៅក្រោយពេលចេញផ្កាពេញលេញប្រមាណជា៣៥ថ្ងៃ ពោលគឺនៅពេលដែលគ្រាប់វាមានអត្រាសំណើមពី២០-២៤% មានសភាពរឹង តែមិនស្លេយនៅពេលខាំឬមានកម្រិតទុំក្នុងកួរឬក្នុងស្រែពី៨០-៨៥%។ បើការច្រូតកាត់យឺតនឹងធ្វើឱ្យគ្រាប់ស្រូវស្ងួតជ្រុលឬទុំញ្ញោស ហើយជ្រុះខ្ចាត់ខ្ចាយច្រើន ព្រមទាំងធ្វើឱ្យងាយប្រេះស្រាំនៅពេលបោកបែន ហើយបាក់ខ្ទេចគ្រាប់អង្ករនៅពេលកិន។ តែបើឆាប់ច្រូតពេក គ្រាប់ស្រូវជាច្រើននឹងនៅស្ទើរ ធ្វើឱ្យពិបាកបោកបែន គ្រាប់មានភាពស្តើង មានសាច់ខាងក្នុងផុស១ដូចដីស ធ្វើឱ្យមានកន្ទក់និងមានចុងអង្ករច្រើននៅពេលកិនជាអង្ករ។

៣- ត្រូវដាក់កណ្តាប់ដែលច្រូតកាត់រួចនៅកន្លែងស្ងួត ឱ្យផុតពីទឹកឬដីសើម ដើម្បីចៀសវាងការធ្វើឱ្យទទឹកគ្រាប់ស្រូវហើយត្រូវប្រញាប់ធ្វើការបោកបែន។ ការទុកកណ្តាប់ចោលយូរនៅក្នុងស្រែ អាចនឹងធ្វើឱ្យគ្រាប់ស្រូវងាយខូចខាតដោយទឹកភ្លៀង ទឹកសន្សើម ការប្រែប្រួលអាកាសធាតុរវាងពេលយប់និងពេលថ្ងៃ ក៏ដូចជាការបំផ្លាញរបស់សត្វស្លាប សត្វកណ្តុរ និងសត្វចង្រៃផ្សេង១ទៀត។

៤- ការប្រមូលនិងដឹកជញ្ជូនកណ្តាប់ស្រូវទៅកាន់ទីលានបោកបែន ត្រូវធ្វើដោយប្រុងប្រយ័ត្ន ដើម្បីចៀសវាងការជ្រុះខ្ចាត់ខ្ចាយគ្រាប់ស្រូវ។ ម្យ៉ាងទៀត ដើម្បីរក្សាភាពសុទ្ធនៃពូជរបស់ស្រូវ កសិករត្រូវចៀសវាងកុំប្រមូល ដឹកនិងបោកបែនកណ្តាប់ស្រូវដែលមានពូជលាយចម្រុះគ្នា។

៥- ត្រូវបោកបែនស្រូវដោយប្រុងប្រយ័ត្ន ចៀសវាងកុំធ្វើឱ្យគ្រាប់ស្រូវបែក ប្រេះស្រាំ និងរលាត់ ដែលធ្វើឱ្យវាងាយទទួលរងផលប៉ះពាល់មិនល្អពីអាកាសធាតុ ការបំផ្លាញពីជំងឺនិងសត្វចង្រៃនានា ជាពិសេសធ្វើឱ្យគ្រាប់អង្ករបាក់ខ្ទេចនៅពេលកិន។

៦- នៅពេលបោកបែនដោយម៉ាស៊ីន ត្រូវសម្រួលឱ្យត្បាល់ម៉ាស៊ីនវិលក្នុងល្បឿនសមស្របគឺ ៦០០ជុំ/នាទី ឬចុងធ្មេញត្បាល់រត់ក្នុងល្បឿន ១២ ម៉ែត្រ/វិនាទី។ ក្នុងករណីដែលល្បឿននេះទាបពេក គឺធ្វើឱ្យម៉ាស៊ីនបោកយឺតឬប្រឡេះគ្រាប់ស្រូវចេញពីចំបើងមិនអស់ ផ្ទុយទៅវិញបើល្បឿននេះលឿនពេក គឺធ្វើឱ្យគ្រាប់ស្រូវរងនូវកម្លាំងវាយផ្ទប់ខ្លាំងដែលធ្វើឱ្យងាយបែកឬរលាត់សម្បកនិងប្រេះស្រាំអង្ករ។

៧- ត្រូវហាលស្រូវនៅពេលមានកម្តៅថ្ងៃល្អគ្រប់គ្រាន់ ក្នុងកម្រាស់ពី២-៥សម នៅលើកន្ទេលឬសំណាញ់។ ករណីហាលលើកម្រាលស៊ីម៉ង់តិ៍ គួរហាលស្រូវក្នុងកម្រាស់ពី៥-១០សម ហើយត្រូវប្រែត្រឡប់ឱ្យបានច្រើនដង (ពី ៧ - ៨ ដង/ថ្ងៃ) ដើម្បីធ្វើឱ្យគ្រាប់ស្រូវស្ងួតសព្វល្អនិងមិនសូវឡើងកម្តៅខ្ពស់។

៨- គួរគ្របឬយកគ្រាប់ស្រូវដែលហាលទៅដាក់ក្នុងម្លប់ នៅពេលព្រះអាទិត្យបញ្ចេញកម្តៅខ្លាំងឬនៅពេលថ្ងៃត្រង់ ដើម្បីចៀសវាងកុំឱ្យសីតុណ្ហភាពឡើងខ្ពស់ជាង៤២អង្សាសេ ដែលអាចនឹងធ្វើឱ្យពូជស្រូវលែងដុះ ហើយ

គ្រាប់អង្ករនឹងប្រេះស្រាំច្រើន ។ សម្រាប់ស្រូវទុកសម្រាប់បរិភោគ គួរហាលឱ្យស្រូវមានអត្រាសំណើម១៤% ហើយសម្រាប់ស្រូវពូជ គួរហាលឱ្យមានអត្រាសំណើម ១២ % ។

៩- ត្រូវសម្អាតគ្រាប់ស្រូវឱ្យបានស្អាតត្រឹមត្រូវល្អ ដោយរែង អុំ រោយឬបក់យកចេញឱ្យអស់នូវគ្រាប់ស្មៅនិងកម្ទេចសំរាមផ្សេងៗ ពីព្រោះភាពមិនស្អាតអាចធ្វើឱ្យស្រូវឡើងកម្តៅ ជាជម្រករបស់សត្វល្អិតនិងកត្តាចង្រៃនានា ដែលអាចបណ្តាលឱ្យស្រូវងាយអន់គុណភាព ។

១០-ចាំបាច់ត្រូវប្រើប្រាស់សម្បកបាវស្ងួតនិងស្អាត ហើយសម្អាតកន្លែងទុកដាក់ឱ្យបានស្អាតជាប្រចាំ។ បើអាចធ្វើបាន គួរទុកដាក់ស្រូវដែលបានហាលស្ងួតល្អនៅក្នុងសម្ភារឬឧបករណ៍ដែលបិទជិតល្អ ។

១១-ត្រូវរៀបចំជង្រុកឬកន្លែងទុកដាក់ស្រូវឱ្យបានសមរម្យនិងអនាម័យល្អ ដោយមានដំបូលនិងជញ្ជាំងគត់មត់ដើម្បីការពារកុំឱ្យគ្រាប់ស្រូវរងសំណើមនិងកម្តៅថ្ងៃ ព្រមទាំងការពារឱ្យបានល្អពីការបំផ្លាញរបស់កត្តាចង្រៃផ្សេងៗ ។

១២-មិនត្រូវយកស្រូវដែលហាលស្ងួតទៅជ្រលក់ទឹកដើម្បីធ្វើឱ្យសើមនិងឡើងទម្ងន់វិញទេ ពីព្រោះអាចធ្វើឱ្យគ្រាប់អង្ករប្រេះនិងបាក់ខ្ទេចនៅពេលកិនហើយមានពណ៌សម្បុរមិនល្អ ដែលនឹងធ្វើឱ្យមានតម្លៃទាបនៅពេលលក់។ ត្រូវចងចាំថា ស្រូវដែលមានសំណើមជាប់នៅក្នុងស្រែពុំសូវមានគ្រាប់ប្រេះស្រាំច្រើនដូចស្រូវដែលស្ងួតហើយផ្សើមដោយទឹកវិញនោះឡើយ ។

១៣-ត្រូវយកចិត្តទុកដាក់ដាស់តឿនក្រើនរំលឹកដល់ប្រជាកសិករឱ្យមានការប្រុងប្រយ័ត្នខ្ពស់អំពីការពន្លត់ភ្លក់ភ្លើងនៅតាមវាលស្រែ ឬក្នុងព្រៃដែលជាមូលហេតុបង្កឱ្យមានភ្លើងឆេះស្រូវជាយថាហេតុនិងត្រូវយកបទពិសោធន៍ពីឆ្នាំមុនៗសម្រាប់ជាមេរៀនអនុវត្តក្នុងឆ្នាំនេះឱ្យមានប្រសិទ្ធភាព ។

ទទួលបាននូវសេចក្តីណែនាំនេះ គ្រប់អង្គភាពក្រោមឱវាទក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទនិងមន្ទីរកសិកម្មរាជធានី-ខេត្ត ត្រូវសហការឱ្យបានល្អនិងមានវិធានការជាបន្ទាន់ជាមួយអាជ្ញាធរមូលដ្ឋាន សមត្ថកិច្ចពាក់ព័ន្ធ ព្រមទាំងកសិករ ម្ចាស់ម៉ាស៊ីនកិនស្រូវនិងអ្នកទិញ-លក់ស្រូវអង្ករ ដើម្បីចូលរួមទប់ស្កាត់ការបាត់បង់ទាំងបរិមាណនិងគុណភាពស្រូវរដូវវស្សាឆ្នាំ២០១១ ទាំងនៅក្នុងនិងនៅក្រោយពេលប្រមូលផល សំដៅរួមចំណែកអនុវត្តគោលនយោបាយរបស់រាជរដ្ឋាភិបាលស្តីពីការជំរុញផលិតកម្មស្រូវនិងការនាំចេញអង្ករឱ្យទទួលបានជោគជ័យ ក្នុងន័យធានាបាននូវសន្តិសុខស្បៀង ការកាត់បន្ថយភាពក្រីក្រនិងការពន្លឿនកំណើនសេដ្ឋកិច្ចជាតិ ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ១៦ ខែ [illegible] ឆ្នាំ ២០១១

រដ្ឋមន្ត្រី

ចាន់ សារុន

**កន្លែងទទួល:**

- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- ក្រសួងផែនការ
- ក្រសួងពាណិជ្ជកម្ម
- ក្រសួងធនធានទឹក និងឧតុនិយម
- ក្រសួងអភិវឌ្ឍន៍ជនបទ
- ក្រសួងព័ត៌មាន
- ក្រុមប្រឹក្សាស្តារអភិវឌ្ឍន៍វិស័យកសិកម្ម និងជនបទ
- ខុទ្ទកាល័យសម្តេចតេជោនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឯកឧត្តមលោកជំទាវឧបនាយករដ្ឋមន្ត្រី
- គ្រប់សាលារាជធានី ខេត្ត

*"ដើម្បីជូនជ្រាប"*

- គ្រប់អង្គភាពពាក់ព័ន្ធ ក្រោមឱវាទក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- គ្រប់មន្ទីរកសិកម្មរាជធានី ខេត្ត

*"ដើម្បីអនុវត្ត"*

- ឯកសារ កាលប្បវត្តិ